ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២៣

នៅក្នុងឆ្នាំ២០២៣នេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន ៖**

-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០៦លើក។

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១២លើក ប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០៧លើក។

ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ

-អនុញ្ញាតឱ្យគណៈប្រតិភូនារី ចំនួន២០០នាក់ ដឹកនាំដោយលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចូលជួបសម្តែងការគួរសម និងរាយការណ៍អំពីវឌ្ឍនភាពការងារនារី នៅវិមានព្រឹទ្ធសភា

-អនុញ្ញាតឱ្យឯកអគ្គរាជទូតតែងតាំងថ្មី ចំនួន១៥រូប នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសជាមិត្ត ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ នៅវិមានព្រឹទ្ធសភា

-អនុញ្ញាតឱ្យឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មី នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត សាធារណរដ្ឋអ៊ុយក្រែន សាធារណរដ្ឋអាស៊ែបៃហ្សង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា

-អញ្ជើញជួបសវនាការ សម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ឥស្សរជនជាន់ខ្ពស់ និងអង្គទូតនានា ចំនួន១៦លើក រួមមាន៖ ប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងលោកជំទាវ, ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងគណៈប្រតិភូ, នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ, នាយករដ្ឋមន្ត្រី



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

នៃប្រទេសម៉ាឡេស៊ី និងគណៈប្រតិភូ, ប្រធានរដ្ឋសភានៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ និងគណៈប្រតិភូ, ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ, អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន, អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាពប្រឹក្សានយោបាយប្រជាជនចិន, សមាជិកព្រឹទ្ធសភាកាណាដា និងគណៈប្រតិភូ, ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតនៃព្រះរាជាណាចក្រជប៉ុន, ព្រះរាជាណាចក្រថៃ, សាធារណរដ្ឋកូរ៉េ, សាធារណរដ្ឋឥណ្ឌូណេស៊ី, ប្រទេសអូស្ត្រាលី និងប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

គ-សកម្មភាពចុះមូលដ្ឋាន

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១៩លើក។

ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៤២លើក។

ង-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៧៦០ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥២១ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០៧លើក។

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១៩លើក ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០៩លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក

-អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យ

-អញ្ជើញចូលរួមសិក្ខាសាលា វេទិកា និងកិច្ចប្រជុំនានា ចំនួន០៦លើក។

ខ-បដិសណ្ឋារកិច្ចឡើងជាតិ-អន្តរជាតិ

-អញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ SHEN Yueyue អនុប្រធាន

គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមា-និតចិន នៅវិមានព្រឹទ្ធសភា

-អញ្ជើញទទួល និងរៀបចំពិធីលៀងសាយភោជនផ្លូវការជូនជាកិត្តិយសដល់លោកជំទាវ SHEN Yueyue អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

គ-សកម្មភាពចុះមូលដ្ឋាន

-អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១២លើក។

ឃ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន០៦លើក។

ង-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៧៣ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៤៧៥ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា បាន ៖**

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១៩លើក ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០៩លើក ដឹកនាំ និងចូលរួមប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០២លើក

-អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យ

-អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារសម្រាប់អនុវត្តតាមផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ នៅវិមានព្រឹទ្ធសភា។

ខ-បេសកកម្មក្រៅប្រទេស

-អញ្ជើញអមព្រះរាជដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ព្រះករុណាព្រះបាទសម្តេច

**ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋឥណ្ឌា

-អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជាទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA- 44) នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ក្នុងឱកាសនោះ ឯកឧត្តម កិត្តិសង្គហបណ្ឌិត **ទេព ងន** ប្រធានគណៈប្រតិភូបានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្តម XHU YONGGUAN សមាជិកសភាតំណាងប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន, លោកជំទាវ SOUNTHONE XAYACHACK អនុប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងឯកឧត្តម **វឿង ឌីញហេ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

គ-សកម្មភាពចុះមូលដ្ឋាន

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន កងកម្លាំងការពារព្រំដែន និងប្រជាពលរដ្ឋនៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១៥លើក។

ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៣១លើក។

ង-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៥០៤ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៩៧ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកកិច្ចប្រជុំ ចំនួន២០លើក ដើម្បី៖

១-ពិនិត្យ និងសម្រេចលើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ ចំនួន២៣ច្បាប់

២-ពិនិត្យ និងសម្រេចរបាយការណ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០, លើកទី១០ និងលើកទី១១ នីតិកាលទី៤

៣-ពិនិត្យ និងសម្រេចរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០២២ និងការបែងចែកឥណទានឆ្នាំ២០២៣។

## ៣.សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

ព្រឹទ្ធសភាបានប្រជុំពេញអង្គ និងប្រជុំជាវិសាមញ្ញ ចំនួន១២លើក ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ ចំនួន២៣ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន

៤-សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

៥-សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

៦-សេចក្តីព្រាងច្បាប់ស្តីពី សារពើពន្ធ

៧-សេចក្តីព្រាងច្បាប់ស្តីពី លទ្ធកម្មសាធារណៈ

៨-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងទឹកស្អាត

៩-សេចក្តីព្រាងក្រម បរិស្ថាន និងធនធានធម្មជាតិ

១០-សេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

១១-សេចក្តីព្រាងច្បាប់ស្តីពី វិធានដើមកំណើតទំនិញ

១២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ខ្មែរអេឡិកទ្រិខល ផៅវ័រ សម្រាប់អនុវត្តគម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល អានុភាព៧០ មេហ្គាវ៉ាត់ ផ្គួបគ្នាជាមួយគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុត អានុភាព១០០ មេហ្គាវ៉ាត់ ខេត្តកោះកុង

១៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឡាក់ឃីសូឡា ផៅវ័រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៨០ មេហ្គាវ៉ាត់ ខេត្តព្រៃវែង

១៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០ មេហ្គាវ៉ាត់ ខេត្តពោធិ៍សាត់

១៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល

នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេចេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយ ផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០ មេហ្គាវ៉ាត់ ខេត្តស្វាយរៀង

១៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេចេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយ ផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០ មេហ្គាវ៉ាត់ ខេត្តកំពង់ឆ្នាំង

១៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្ទឹងមេទឹក សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹង មេទឹក អានុភាព១៥០ មេហ្គាវ៉ាត់ ខេត្តកោះកុង

១៨-សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតក្រសួងអធិការកិច្ច

១៩-សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

២០-សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

២១-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

២២-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

២៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ច គ្រប់ជ្រុងជ្រោយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួម

២៤-ស្តាប់របាយការណ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះ សម័យប្រជុំលើកទី៩ និងលើកទី១០, លើកទី១០ និងលើកទី១១ នីតិកាលទី៤។

**៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ច របស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៤.១-មុខងារនីតិកម្ម**

-គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ និង សេចក្តីស្នើច្បាប់ ចំនួន២៣ច្បាប់

-បានប្រជុំគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល២០២៤-២០២៦ និងគម្រោង ថវិកាប្រចាំឆ្នាំ២០២៤ របស់ព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយ ឯកឧត្តម **ចាន់ សុធី** និងឯកឧត្តម **ម៉ឹង មករា** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាប្រចាំឆ្នាំ២០២៤ របស់ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងឆ្លងឯកសារស្ដីពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

**៤.២-មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញចុះបេសកកម្ម ចំនួន១៩លើក ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ ការអនុវត្តគោលនយោបាយនានា, ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ, ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការគ្រប់គ្រងថែទាំកុមារ, ការគ្រប់គ្រងកិច្ចអភិរក្ស និងការអភិវឌ្ឍវិស័យទេសចរណ៍, ការងារមូលនិធិ, បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង ខេត្តកែប ខេត្តកំពត ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តកំពង់ស្ពឺ

-បានអញ្ជើញជួបសវនាការការងារ ចំនួន១០លើក ជាមួយគណៈប្រតិភូក្រសួង ស្ថាប័ននានា រួមមាន៖ ក្រសួងព័ត៌មាន, រាជបណ្ឌិត្យសភាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អគ្គនាយកអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ, ប្រធានមន្ទីរអប់រំ យុវជន និងកីឡា, ប្រធានមន្ទីរធម្មការ និងសាសនា, ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងប្រធានមន្ទីរទេសចរណ៍, អាជ្ញាធរមានសមត្ថកិច្ចប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ខេត្តស្ទឹងត្រែង, ប៉ុស្តិ៍នគរបាលប្រចាំការនៅច្រកទ្វារកំពង់ផែអន្តរជាតិភ្នំពេញ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនអន្តោប្រវេសន៍, វឌ្ឍនភាពការងារ បញ្ហាប្រឈម និងទិសដៅអនុវត្តបន្ត

-បានអញ្ជើញចុះបំពេញទស្សនកិច្ចអំពីសក្ដានុពលក្នុងវិស័យកសិកម្ម នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុងឫទ្ធី សែនជ័យ ស្ថិតក្នុងឃុំស្ពុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

**៤.៣-មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹង ចំនួន៣៧បណ្ដឹង ធ្វើកំណត់បង្ហាញពាក្យបណ្ដឹង ចំនួន២៩បណ្ដឹង ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយ ចំនួន២៩បណ្ដឹង កំពុងពិនិត្យសិក្សា ចំនួន០៨បណ្ដឹង ឆ្លើយតបទៅម្ចាស់បណ្ដឹង ចំនួន៣១បណ្ដឹង ទទួលលិខិត

ឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន១២បណ្តឹង និង តម្កល់ទុកមិនចាត់ការ ចំនួន០៨បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹង ចំនួន០២បណ្តឹង ដោះស្រាយបញ្ចប់ ចំនួន០២បណ្តឹង និងទទួលឯកសារពាក្យបណ្តឹងដែល ក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាប ចំនួន១២បណ្តឹង

-ពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅចុងនីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅ វិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុម សមាជិកាព្រឹទ្ធសភា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទី ព្រឹទ្ធសភា

-បានធ្វើវេទិកាសាធារណៈ ចំនួន០២លើក ស្តីពីការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវា ជូនប្រជាជនប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៅទូទាំង១៤ខណ្ឌ ក្នុងរាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ក្រីក្រ ចំនួន២៨លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកែប ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង

-បានអញ្ជើញធ្វើបទបង្ហាញប្រគេន និងជូនព្រះសង្ឃ សាស្ត្រាចារ្យ សិស្ស និងនិស្សិត អញ្ជើញមកធ្វើទស្សនកិច្ចសិក្សាឈ្វេងយល់អំពីតួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា នៅវិមាន ព្រឹទ្ធសភា

-បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកា ពិធីបុណ្យជាតិ-អន្តរ ជាតិ និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន១.២០៨លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ មន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ, ការងារសន្តិសុខសណ្តាប់ធ្នាប់, ការផ្តល់សេវា សាធារណៈជូនប្រជាពលរដ្ឋ, ការអនុវត្តគោលនយោបាយនានា, ការកសាង និងពិនិត្យ

ហេដ្ឋារចនាសម្ព័ន្ធ, សម្ពោធសមិទ្ធផលនានា, នាំយកអំណោយ និងដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ នៅតាមបណ្តាខេត្ត ក្រុង នានា ចំនួន១,៤៦៦លើក។

**៤.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា ចំនួន២១លើក មានជាអាទិ៍៖ កិច្ចប្រជុំអាស៊ី-ប៉ាស៊ីហ្វិក(APG) នៃមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៦ នៅព្រះរាជាណាចក្របារ៉ែន, កិច្ចប្រជុំក្រុមមិត្តភាពនៃសភាកម្ពុជា-វៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម, កិច្ចប្រជុំក្រុមការងារសើរើលក្ខន្តិកៈ និងកិច្ចប្រជុំគណៈកម្មការនយោបាយ(APF) នៅសាធារណរដ្ឋបារាំង, កិច្ចប្រជុំគណៈកម្មការកិច្ចការសភា(APF) និងបណ្តាញស្ត្រីនៃសភាប្រើប្រាស់ភាសាបារាំង នៅព្រះរាជាណាចក្រម៉ារ៉ុក, កិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន នៅសាធារណរដ្ឋឥណ្ឌូនេស៊ី, កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) នៅប្រទេសហ្សកហ្ស៊ី, កិច្ចប្រជុំវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៧ ស្តីពីសុខភាពសកល (APPFGH-7) នៅប្រទេសម៉ុងហ្គោលី, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ាលើកទី១៤ The 14th AIPA Caucus Meeting នៅសាធារណរដ្ឋសង្គមនិយមវៀតណាម, មហាសន្និបាតលើកទី១៣ នៃសភាតំបន់អាស៊ី(APA) នៅសាធារណរដ្ឋតួកគី, មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) ក្រោមប្រធានបទស្តីពីការឆ្លើយតបសភា ដើម្បីស្ថិរភាព និងវិបុលភាពអាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី, មហាសន្និបាតលើកទី៤៨ នៃសភាប្រើសភាបារាំង APF-48 នៅប្រទេសហ្សកហ្ស៊ី, សិក្ខាសាលាអន្តរតំបន់ឆ្នាំ២០២៣ ក្រោមប្រធានបទ ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់សភាកំពុងអភិវឌ្ឍន៍ នៅសាធារណរដ្ឋប្រជាមានិតចិន, សិក្ខាសាលាសមាជិកសភាស្តីពីអភិបាលកិច្ចតាមប្រព័ន្ធឌីជីថល និងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណែត នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, វេទិកាថ្នាក់ដឹកនាំអាស៊ាន-កូរ៉េ (ASEAN-Korea Leader Forum) នៅសាធារណរដ្ឋកូរ៉េ, មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៧ (IPU-147) ប្រទេស Angola, មហាសន្និបាតប្រចាំឆ្នាំលើកទី៥ និងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅប្រទេសកាណាដា, មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រមសីលធម៌សមាជិកហ្វ្រង់កូហ្វូនី នៅប្រទេសកាណាដា, កិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៣១ (APPF-31) នៅសាធារណរដ្ឋហ្វីលីពីន, កិច្ចប្រជុំក្រុមការងារសើរើលក្ខន្តិកៈAPF នៅប្រទេសស្វីស Suisse, កិច្ចប្រជុំកំពូលសភា កម្ពុជា-ឡាវ-វៀតណាម (CLV) លើកទី១ ស្តីពីការពង្រឹងតួនាទីសភាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនៃប្រទេសទាំងបី នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសវនាការ ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយគណៈប្រតិភូអន្តរជាតិ អង្គទូត និងអ្នកវិនិយោគគិននានា ចំនួន២០លើក។

ថ្ងៃ ៥ ៨ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៤

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

ចម្លងជូន:

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន

(ជូនជ្រាបជាព័ត៌មាន)

- កាលប្បវត្តិ-ឯកសារ